ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
រដ្ឋបាលខេត្តកំពង់ធំ
លេខ ៖ ៤០៤ សជណា

# សេចក្ដីជូនដំណឹង

**យោង** ៖ ប្រកាសលេខ ១៥៣៥ ប្រក ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៤ ស្ដីពីការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០១៤។

រដ្ឋបាលខេត្តកំពង់ធំសូមជូនដំណឹងដល់ សិស្ស និស្សិត ដែលមានបំណងចង់ចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃឱ្យបានជ្រាបថា ៖ ក្រសួងមហាផ្ទៃសម្រេចបើកឱ្យមានការប្រឡងជ្រើសរើស សិស្ស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០១៤ នៅសាលាខេត្តកំពង់ធំ និងនៅតាមបណ្ដាក្រុង ស្រុកមួយចំនួនដូចមានខាងក្រោម ៖

***១-សាលាខេត្តកំពង់ធំ***

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ៖ ចំនួន ០១ នាក់
- ក្របខ័ណ្ឌមន្ត្រីក្រមការ ៖ ចំនួន ០១ នាក់
- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ ចំនួន ០២ នាក់

***២-សាលាក្រុងស្ទឹងសែន***

- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ ចំនួន ០២ នាក់

***៣-សាលាស្រុកស្ទោង***

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ៖ ចំនួន ០១ នាក់
- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ ចំនួន ០២ នាក់

***៤-សាលាស្រុកកំពង់ស្វាយ***

- ក្របខ័ណ្ឌមន្ត្រីក្រមការ ៖ ចំនួន ០២ នាក់
- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ ចំនួន ០២ នាក់

***៥-សាលាស្រុកសន្ទុក***

- ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ៖ ចំនួន ០១ នាក់
- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ ចំនួន ០២ នាក់

***៦-សាលាស្រុកបារាយណ៍***

- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ ចំនួន ០២ នាក់

***៧-សាលាស្រុកប្រាសាទសំបូរ***

- ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ ចំនួន ០២ នាក់

***ក-លក្ខខណ្ឌនៃការជ្រើសរើស ៖***

១- មានសញ្ជាតិខ្មែរ

២- មានកាយសម្បទាគ្រប់លក្ខណៈ មានសុខភាពល្អ និងជនពិការមានសមត្ថភាពសមស្រប

៣- មិនប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិជាពលរដ្ឋ

៤- បេក្ខជនត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ ។ ការកម្រិតអាយុត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣០ឆ្នាំ យ៉ាងច្រើនបំផុតចំពោះបេក្ខជន ដែលមានសញ្ញាប័ត្រឧត្តមសិក្សា ។

៥- ចំពោះបេក្ខនារី ជនពិការដែលមានសមត្ថភាព និងបេក្ខជននៅតំបន់ដាច់ស្រយាលត្រូវបានផ្ដល់ការលើកទឹកចិត្តនៅក្នុងការប្រឡងជ្រើសរើសនេះ ។

៦- បេក្ខជនត្រូវមានសញ្ញាបត្រ ៖

-ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ៖ បេក្ខជនទាំងពីរភេទជា សិស្ស និស្សិតត្រូវមានសញ្ញាប័ត្របរិញ្ញាបត្រនីតិសាស្ត្រ បរិញ្ញាបត្រសេដ្ឋកិច្ច បរិញ្ញាបត្រស្ថាបត្យកម្ម បរិញ្ញាបត្រព័ត៌មានវិទ្យា ឬសញ្ញាប័ត្របរិញ្ញាបត្រដែលមានតម្លៃស្មើ ។

-ក្របខ័ណ្ឌមន្ត្រីក្រមការ ៖ បេក្ខជនទាំងពីរភេទជា សិស្ស និស្សិត ត្រូវមានសញ្ញាបត្រយ៉ាងទាបមធ្យមសិក្សានីតិសាស្ត្រ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ ។

-ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖ បេក្ខជនទាំងពីរភេទជាសិស្សត្រូវមានសញ្ញាបត្រយ៉ាងទាបបំផុតសមមូល នឹងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។

**ខ-វិញ្ញាសា និងថេរវេលាប្រឡង ៖**

-ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ៖

១- ជំនាញឯកទេស .......................................... រយៈពេល ០១ ម៉ោង ៣០ នាទី

២- ភាសាអង់គ្លេស .......................................... រយៈពេល ០១ ម៉ោង ៣០ នាទី

-ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ៖

១- ចំណេះដឹងទូទៅ និងគណិតវិទ្យា .................. រយៈពេល ០១ ម៉ោង ៣០ នាទី

២- តែងសេចក្តី ឬការសរសេរលិខិតរដ្ឋបាល ........រយៈពេល ០១ ម៉ោង ៣០ នាទី

បេក្ខជនដែលមានបំណងចង់ចូលបម្រើការងារត្រូវទៅដាក់ពាក្យសុំចុះឈ្មោះដើម្បីចូលរួមប្រឡងប្រជែងនៅសាលាខេត្តកំពង់ធំ រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ម៉ោង ១៧.០០ នាថ្ងៃ សុក្រ ទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ ជាកាលកំណត់ចុងក្រោយ ។

**❋ មណ្ឌលប្រឡង កាលបរិច្ឆេទប្រឡង**

-ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ

-ក្របខ័ណ្ឌលេខាធិការរដ្ឋបាល

-មណ្ឌលប្រឡង ៖ ខេត្តកំពង់ធំ ( កំពង់ធំ សៀមរាប ព្រះវិហារ )

-កាលបរិច្ឆេទប្រឡង ៖ នៅថ្ងៃ អាទិត្យ ទី ២៩ ខែ មិថុនា ឆ្នាំ ២០១៤

ព័ត៌មានផ្សេងៗទៀត សូមអញ្ជើញទាក់ទងផ្ទាល់នៅការិយាល័យគ្រប់គ្រងបុគ្គលិកសាលាខេត្តកំពង់ធំ រៀងរាល់ម៉ោងធ្វើការ ឬតាមរយៈ

១-លោក សូត៌ ច័ន្ទតារា ប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក

លេខទូរស័ព្ទ ៖ ០៧៧ ៧១ ៣១ ៧១ ,០៩៧ ៧៦ ៤៤៤ ៥៦ ,០៦៩ ៦៥៩ ៥៦៩

២-លោកស្រី គៀន ធារី អនុប្រធានការិយាល័យគ្រប់គ្រងបុគ្គលិក

លេខទូរស័ព្ទ៖ ០១៧ ៩២ ១៨ ៣៥ ។

**ចំណាំ ៖** ចំពោះមណ្ឌលប្រឡងសូមទំនាក់ទំនងមកការិយាល័យគ្រប់គ្រងបុគ្គលិក ឲ្យបានមុនមួយថ្ងៃនៃ ថ្ងៃប្រឡង ។

កំពង់ធំ,ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៤

**អភិបាលខេត្ត**

**ចម្លងជូន**

-ក្រសួងមហាផ្ទៃ

-ក្រុមប្រឹក្សាខេត្ត

ដើម្បី " ជូនជ្រាប "

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បី " ជ្រាប "

-មន្ទីរព័ត៌មាន

-គ្រប់សាលាក្រុង- ស្រុក

ដើម្បី " ផ្សព្វផ្សាយ "

-ឯកសារ -កាលប្បវត្តិ